ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ០០៤ សសរ. ធទឧ

# សេចក្ដីសម្រេច

## ស្ដីពីការបង្កើតក្រុមការងាររៀបចំ និងទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូក្រសួងធនធានទឹកនៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយឯកឧត្ដមរដ្ឋមន្ត្រី លី ហ្គួយ៉ុង (Li Guoying) មកកាន់ព្រះរាជាណាចក្រកម្ពុជា

## នៅថ្ងៃទី១៦-១៨ ខែមីនា ឆ្នាំ២០២៥

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងធនធានទឹក និងឧតុនិយម

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារចំពោះកិច្ច និងអនុក្រុមការងារជំនាញ ដើម្បីរៀបចំ និងទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូក្រសួងធនធានទឹកនៃសាធារណរដ្ឋប្រជាមានិតចិនមកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្ដម | **អាន ពេជ្រ ហត្ថា** | រដ្ឋលេខាធិការ ធ.ទ.ឧ | ប្រធាន |
| ២. | ឯកឧត្ដម | **ជួន មិត្តថុល** | អនុរដ្ឋលេខាធិការ ធ.ទ.ឧ | អនុប្រធាន |
| ៣. | លោកជំទាវ | **វ៉ាន់ ចាន់ថូ** | អនុរដ្ឋលេខាធិការ ធ.ទ.ឧ | អនុប្រធាន |
| ៤. | ឯកឧត្ដម | **សេរី បណ្ឌិត** | អនុរដ្ឋលេខាធិការ ធ.ទ.ឧ | អនុប្រធាន |
| ៥. | ឯកឧត្ដម | **ហូ សិទ្ធីច័ន្ទ** | អនុរដ្ឋលេខាធិការ ធ.ទ.ឧ | អនុប្រធាន |



# អគារលេខ: ៣៦៤ មហាវិថី ព្រះមុនីវង្ស សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៦ ៦៧០
#364, Monivong BLVD, Phsar Deumthkov, Chamkarmon, Phnom Penh, Cambodia, Phone: (855)23 216 670

| | | | | |
|---|---|---|---|---|
| ៦. | ឯកឧត្តម | **ហ៊ើល តូនី** | អនុប្រធានអចិន្ត្រៃយ៍ អ.ទ.ស | សមាជិក |
| ៧. | ឯកឧត្តម | **ម៉េង ប៉ូគន្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ៨. | ឯកឧត្តម | **ឈុន ពុទ្ធារិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស | សមាជិក |
| ៩. | ឯកឧត្តម | **សូ សុភ័ន្ធ** | អគ្គលេខាធិការ គ.ជ.ទ.ម.ក | សមាជិក |
| ១០. | ឯកឧត្តម | **សរ គឹមសាន្ត** | អគ្គលេខាធិការ អ.ទ.ស | សមាជិក |
| ១១. | លោក | **ម៉ម ប្រុស** | ប្រធាននាយកដ្ឋាន ធ.ទ.ឱ | សមាជិក |
| ១២. | លោក | **ឃ្លោក សំអាង** | ប្រធាននាយកដ្ឋាន ធ.ទ.ឱ | សមាជិក |

**ប្រការ២ ._**

ក្រុមការងារចំពោះកិច្ចនេះ មានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ទទួលខុសត្រូវរួមក្នុងការដឹកនាំ រៀបចំ ចាត់តាំង និងណែនាំសកម្មភាពរបស់អនុក្រុមការងារនានា ដើម្បីធានាឱ្យការរៀបចំ និងការទទួលបដិសណ្ឋារកិច្ចរបស់គណៈប្រតិភូក្រសួងធនធានទឹក នៃសាធារណៈរដ្ឋប្រជាមានិតចិនមកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលគ្រោងឡើងនៅថ្ងៃទី១៦-១៨ ខែមីនា ឆ្នាំ២០២៥ ប្រព្រឹត្តទៅដោយជោគជ័យ
- ដឹកនាំ ពិនិត្យ និងណែនាំលើការរៀបចំរបៀបវារៈលម្អិត ខ្លឹមសារឯកសារនានា និងការងារពិធីការនៃការទទួលបដិសណ្ឋារកិច្ច
- ដឹកនាំ ពិនិត្យ និងណែនាំលើកិច្ចដំណើរការផ្សេងទៀតពាក់ព័ន្ធនឹងការរៀបចំទទួលបដិសណ្ឋារកិច្ច ដែលបានស្នើដោយអនុក្រុមការងារ
- ប្រធានអង្គភាពទាំងអស់ អាចប្រើប្រាស់មន្ត្រីរបស់ខ្លួនដើម្បីជួយបំពេញការងារតាមការចាំបាច់
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចពី ឯកឧត្តមរដ្ឋមន្ត្រី។

**ប្រការ៣ ._**

បង្កើតអនុក្រុមការងារជំនាញ ដើម្បីជួយការងារដល់ក្រុមការងារចំពោះកិច្ច ដែលមានសមាសភាពដូចខាងក្រោម៖

### ក. អនុក្រុមការងារទទួលបន្ទុកការងាររៀបចំខ្លឹមសារ និងឯកសារចាំបាច់នានា

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **សេរី បណ្ឌិត** | អនុរដ្ឋលេខាធិការ ធ.ទ.ឱ | ប្រធាន |
| ២. | ឯកឧត្តម | **សូ សុភ័ន្ធ** | អគ្គលេខាធិការ គ.ជ.ទ.ម.ក | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. | ឯកឧត្តម | **ឈុន ពុទ្ធារិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស | អនុប្រធាន |
| ៤. | លោក | **ជឹម កុសល** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស | សមាជិក |
| ៥. | លោក | **ឃ្លោក សំអាង** | ប្រធាននាយកដ្ឋាន ធ.ទ.ឱ | សមាជិក |
| ៦. | លោក | **ខួន វិចិត្រ** | ប្រធាននាយកដ្ឋាន គ.ជ.ទ.ម.ក | សមាជិក |
| ៧. | លោក | **ហេង បូរាណ** | អនុប្រធាននាយកដ្ឋាន អ.ទ.ស | សមាជិក |
| ៨. | លោក | **ប៊ុន ចន្ថា** | អនុ.ការិយាល័យ ធ.ទ.ឱ | សមាជិក |
| ៩. | លោក | **ស៊ាម លីហ៊ាង** | អនុ.ការិយាល័យ ធ.ទ.ឱ | សមាជិក |
| ១០. | លោក | **នេត វាសនា** | អនុ.ការិយាល័យ ធ.ទ.ឱ | សមាជិក |
| ១១. | លោក | **សាន អង្គដែន** | អនុ.ការិយាល័យ ធ.ទ.ឱ | សមាជិក |
| ១២. | លោក | **ឈឿង ចំរើន** | អនុ.ការិយាល័យ គ.ជ.ទ.ម.ក | សមាជិក |

អនុក្រុមការងារនេះ មានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- រៀបចំសុន្ទរកថា ឯកសារជំនួយស្មារតី និងឯកសារផ្សេងៗសម្រាប់ជូនឯកឧត្តមរដ្ឋមន្ត្រី
- រៀបចំកម្មវិធីលម្អិតនៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូក្រសួងធនធានទឹកចិន ដោយប្រើប្រាស់កម្មវិធីគោលដែលបានព្រមព្រៀងគ្នា
- កត់ត្រា និងរៀបចំកំណត់ហេតុសម្រាប់កិច្ចប្រជុំនានានិងព្រឹត្តិការណ៍ ព្រមទាំងធ្វើរបាយការណ៍បូកសរុបនៃដំណើរទស្សនៈកិច្ច
- រាយការណ៍អំពីវឌ្ឍនភាពការងាររបស់អនុក្រុមការងារជូនក្រុមការងារចំពោះកិច្ចពិនិត្យ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមការងារចំពោះកិច្ច។

**ខ. អនុក្រុមការងារទទួលបន្ទុកការងាររដ្ឋបាល និងបដិសណ្ឋារកិច្ច**

| | | | | |
|---|---|---|---|---|
| ១. | លោកជំទាវ | **វ៉ាន់ ចាន់ថូ** | អនុរដ្ឋលេខាធិការ ធ.ទ.ឧ | ប្រធាន |
| ២. | ឯកឧត្តម | **ម៉េង ម៉ុគន្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. | ឯកឧត្តម | **សរ គឹមសាន្ត** | អគ្គលេខាធិការ អ.ទ.ស | អនុប្រធាន |
| ៤. | លោក | **ម៉ម ប្រុស** | ប្រធាននាយកដ្ឋាន ធ.ទ.ឧ | សមាជិក |
| ៥. | លោក | **ឃ្លោក សំអាង** | ប្រធាននាយកដ្ឋាន ធ.ទ.ឧ | សមាជិក |
| ៦. | លោក | **យ៉ាន់ សំរិទ្ធ** | ប្រធាននាយកដ្ឋាន អ.ទ.ស | សមាជិក |
| ៧. | លោកស្រី | **ហេង រស្មីផល្លា** | ប្រធានការិយាល័យ ធ.ទ.ឧ | សមាជិក |
| ៨. | លោក | **ទុយ ចាន់សីហា** | អនុ.ការិយាល័យ ធ.ទ.ឧ | សមាជិក |
| ៩. | លោក | **ទុង ចាន់ឡា** | អនុ.ការិយាល័យ ធ.ទ.ឧ | សមាជិក |
| ១០. | លោក | **ចេង ខុំ** | អនុ.ការិយាល័យ គ.ជ.ទ.ម.ក | សមាជិក |
| ១១. | លោក | **ម៉ែន អធិការ** | អនុព័ន្ធសភា | សមាជិក |
| ១២. | លោកស្រី | **តាំង ដាវី** | ជំនួយការ | សមាជិក |
| ១៣. | លោក | **លឹម លិប្សា** | មន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៤. | លោក | **ពេជ្រ ចំរើន** | មន្ត្រីបច្ចេកទេស គ.ជ.ទ.ម.ក | សមាជិក |
| ១៥. | លោកស្រី | **ស៊ិន អង្គារសោធ** | មន្ត្រីកិច្ចសន្យា | សមាជិក។ |

អនុក្រុមការងារនេះមានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- រៀបចំបញ្ជី (Checklist) រាល់សកម្មភាពដែលចាំបាច់ជានាដល់ការរៀបចំផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ភស្តុភារ និងពិធីការ
- សម្របសម្រួលរាល់ការចេញលិខិតស្នាម និងឯកសាររដ្ឋបាលពាក់ព័ន្ធដែលបម្រើដល់ការងារទទួលបដិសណ្ឋារកិច្ច
- រៀបចំកិច្ចប្រជុំទ្វេភាគី ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា និងដំណើរទស្សនកិច្ចទៅតាមតំបន់គោលដៅដែលបានឯកភាព
- រៀបចំចាត់ចែងពិធីការទទួលបដិសណ្ឋារកិច្ច ដោយគោរពបានតាមស្តង់ដារពិធីការ ដើម្បីធានាឱ្យបានដំណើរទស្សនកិច្ចរបស់គណៈប្រតិភូចិន ប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ
- រៀបចំចាត់ចែង និងសម្របសម្រួលការងារសន្តិសុខរបស់គណៈប្រតិភូ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធានាសុវត្ថិភាព ការធ្វើដំណើរ និងការស្នាក់នៅរបស់សមាជិកគណៈប្រតិភូ
- ទំនាក់ទំនងជាមួយភាគីចិន លើកម្មវិធីលម្អិតរបស់គណៈប្រតិភូចិន
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមការងារចំពោះកិច្ច។

## គ. អនុក្រុមការងារទទួលបន្ទុកការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ហូ សិទ្ធីវ័ន្ត** | អនុរដ្ឋលេខាធិការ ធ.ទ.ឧ | ប្រធាន |
| ២. | ឯកឧត្តម | **ម៉េង ប៉ូគន្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល | អនុប្រធាន |
| ៣. | លោកស្រី | **ថោ ជេដ្ឋវេយ្យានា** | អនុពន្ធសារព័ត៌មាន ធ.ទ.ឧ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. | លោក | **ឃ្លោក សំអាង** | ប្រធាននាយកដ្ឋាន ធ.ទ.ឧ | សមាជិក |
| ៥. | លោក | **មុយ មុនិន្ទ** | ប្រធាននាយកដ្ឋាន ធ.ទ.ឧ | សមាជិក |
| ៦. | លោក | **ឌី ផាន់ណា** | អនុប្រធានប្រធាននាយកដ្ឋាន ធ.ទ.ឧ | សមាជិក |
| ៧. | កញ្ញា | **ម៉ៃ សុវណ្ណារស្មី** | ជំនួយការក្រសួង ធ.ទ.ឧ | សមាជិក |

អនុក្រុមការងារនេះមានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- រៀបចំគម្រោងចំណាយ គ្រប់គ្រងការបែងចែក និងប្រើប្រាស់ហិរញ្ញវត្ថុ ទិញសម្ភារៈចាំបាច់ សម្រាប់ផ្គត់ផ្គង់ដល់ការងារទទួលបដិសណ្ឋារកិច្ច
- រៀបចំការទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូជាផ្លូវការ កន្លែងស្នាក់នៅ មធ្យោបាយធ្វើដំណើរ កន្លែងពិសារភោជនីយអាហារ ការរៀបចំពិធីលៀងសាយភោជន៍ទៅតាមការចាំបាច់ ដោយធានាបានគុណភាព និងស្របតាមវប្បធម៌នៃប្រទេសទាំងពីរ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមការងារចំពោះកិច្ច។

**ប្រការ៤ ._**

អនុប្រធាន និងសមាជិកនៃក្រុមការងារចំពោះកិច្ច អនុក្រុមការងារជំនាញ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងអនុវត្តភារកិច្ច តាមការណែនាំ និងប្រគល់ភារកិច្ចដោយប្រធាន។ ក្នុងករណីប្រធានអវត្តមានឬករណីចាំបាច់ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួស។

ក្រុមការងារចំពោះកិច្ច អនុក្រុមការងារជំនាញ មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជំនាញ និងភាគីពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ និងផ្តល់យោបល់តាមការចាំបាច់។

**ប្រការ៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពចំណុះក្រសួងធនធានទឹក និងឧតុនិយម និងសាមីខ្លួនដូចក្នុងប្រការ១ និងប្រការ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ថោ ជេដ្ឋា**

**កន្លែងទទួល៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ